វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី៧ ខែកញ្ញា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ប្រទេសកម្ពុជាគ្រោងនឹងបង្កើតខេត្តថ្មី
- អត្រានិកម្មភាព(អត្រាអ្នកគ្មានការងារ)របស់ប្រទេសហ្វីលីពីនធ្លាក់ចុះ ០,២ពិន្ទុភាគរយ
- ឱនភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក ហក់លោតខ្ពស់ ក្នុងរយៈពេល ៣ឆ្នាំ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ប្រទេសកម្ពុជាគ្រោងនឹងបង្កើតខេត្តថ្មី

នៅថ្ងៃទី ៣០ កក្កដា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់ការអនុញ្ញាតទៅលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការសិក្សាលើការបង្កើតខេត្តថ្មីចំនួនពីរ។ ខេត្តទី១ នឹងបង្កើតឡើងដោយធ្វើការយកផ្នែកមួយចំនួនពីខេត្តមណ្ឌលគិរី និងខេត្តរតនគិរី ចំណែកឯខេត្តមួយទៀត ត្រូវបានបំបែកចេញពីខេត្តកណ្តាល។

មូលហេតុដែលនាំឲ្យមានការបង្កើតខេត្តថ្មី គឺដើម្បីបង្កើនប្រសិទ្ធភាពរដ្ឋបាល រក្សាសន្តិសុខសាធារណៈ ជម្រុញការអភិវឌ្ឍក្នុងតំបន់ និងពង្រឹងការផ្តល់សេវាសាធារណៈ។ រដ្ឋបាលនៃខេត្តថ្មីនេះ នឹងចាប់ផ្តើមដំណើរការនៅពេលឆាប់ៗក្នុងដើមឆ្នាំ ២០១៩ ។

### តារាងប្រចាំសប្តាហ៍៖ ការអនុវត្តសារពើពន្ធ ឆ្នាំ២០១៨

ដោយថវិកាឆ្នាំ២០១៩ ខិតជិតមកដល់ តារាងនៅសប្តាហ៍នេះ នឹងធ្វើការបង្ហាញពីការសរុបសារពើពន្ធរបស់ថវិកាឆ្នាំ២០១៨។

តារាងខាងក្រោម បង្ហាញពីការប្រៀបធៀបច្បាប់ថវិកាឆ្នាំ២០១៨ ទៅនឹងថវិកាអនុវត្តជាក់ស្តែងថ្មីបំផុត ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ផ្នែកចំណូលមានភាពល្អប្រសើរជាងការរំពឹងទុក ដែលនាំឲ្យការប៉ាន់ប្រមាណឡើងវិញនៃចំណូលស្មើនឹង ១៩,៥ភាគរយនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ប្រៀបធៀបជាមួយ១៨,៨ភាគរយនៃផ.ស.សក្នុងច្បាប់ថវិកាឆ្នាំ២០១៨ ។ ផ្នែកចំណាយត្រូវបានអនុវត្តប្រហាក់ប្រហែលនឹងការគ្រោងទុក។ ដូច្នេះ សមាជិកសភាអាចរំពឹងថា ក្នុងឆ្នាំ២០១៨ នឹងមានអតិរេកគណនីចរន្តធំជាងមុន ដែលស្មើនឹង ៣,៣ភាគរយនៃផ.ស.ស ធៀបនឹង ២,៥ភាគរយនៃផ.ស.ស និងឱនភាពសរុបថវិការួមតូចត្រឹម ៥ ភាគរយនៃផ.ស.ស បើធៀបនឹង ៥,៩ភាគរយនៃផ.ស.សក្នុងច្បាប់ថវិកា។

សារពើពន្ធសរុប ថវិកាឆ្នាំ ២០១៨ និងការប៉ាន់ប្រមាណឡើងវិញ

| សូចនាករ | ២០១៨ (ច្បាប់) | ២០១៨ (ប៉ាន់ស្មាន) |
|---|---|---|
| ផ.ស.ស (ប៊ីលានរៀល) | 99,332.2 | |
| ចំណូល (ភាគរយនៃផ.ស.ស) | 18.75% | 19.53% |
| ចំណូលចរន្ត (ភាគរយនៃផ.ស.ស) | 18.57% | 19.35% |
| ចំណាយ (ភាគរយនៃផ.ស.ស) | 24.59% | 24.56% |
| ចំណាយចរន្ត (ភាគរយនៃផ.ស.ស) | 16.09% | 16.08% |
| អតិរេកគណនីចរន្ត (ភាគរយនៃផ.ស.ស) | 2.48% | 3.27% |
| ឱនភាពសរុប (ភាគរយនៃផ.ស.ស) | **-5.84%** | **-5.03%** |

ប្រភព៖ របាយការណ៍លទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## អត្រានិកម្មភាព (អត្រាអ្នកគ្មានការងារ) របស់ប្រទេសហ្វីលីពីនធ្លាក់ចុះ០,២ពិន្ទុភាគរយ

យោងតាមទិន្នន័យចេញផ្សាយដោយអាជ្ញាធរស្ថិតិហ្វីលីពីនក្នុងអាទិត្យនេះបង្ហាញថា ភាពអត់ការងារធ្វើនៅហ្វីលីពីនក្នុងខែកក្កដាបានធ្លាក់ចុះពី ៥,៦ភាគរយ មក៥,៤ភាគរយ បើប្រៀបធៀបទៅនឹងខែកក្កដាឆ្នាំមុន។

យ៉ាងណាមិញ ទិន្នន័យមានលក្ខណៈមិនស្របគ្នា ដោយអត្រាចូលរួមក្នុងកម្លាំងពលកម្មបានថយចុះ ០,៥ពិន្ទុភាគរយ ពី ៦០,៦ភាគរយ មកត្រឹម៦០,១ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំកន្លងទៅ។ នេះអាចបង្ហាញថា ការធ្លាក់ចុះនៃភាពអត់ការងារធ្វើ អាចបណ្តាលមួយផ្នែកមកពីនិយោជិកដែលបាក់ទឹកចិត្ត បានចាកចេញពីកម្លាំងពលកម្ម ។

# សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

## ឱនភាពពាណិជ្ជកម្មនៅសហរដ្ឋអាមេរិក ហក់លោតខ្ពស់បំផុតក្នុងរយៈពេលបីឆ្នាំ

ឱនភាពពាណិជ្ជកម្មនៅសហរដ្ឋអាមេរិកបានកើនឡើងខ្ពស់ប្រមាណ៩,៥ភាគរយ ក្នុងរយៈពេលប្រាំខែ ដែលស្មើនឹង ៥០,១ពាន់លានដុល្លា នៅក្នុងខែកក្កដា ដែលបណ្តាលមកពីការធ្លាក់ចុះនៃការនាំចេញសណ្តែកដី និងយន្តហោះស៊ីវិល ហើយការនាំចូលកើនឡើងខ្ពស់លើសពីកំណត់ត្រា បើតាមរយៈការចុះផ្សាយរបស់នាយកដ្ឋានពាណិជ្ជកម្ម និងការិយាល័យជម្រឿន ដែលចេញផ្សាយក្នុងសប្តាហ៍នេះ។ នេះគឺជាកំណើនក្នុងមួយខែដែលខ្ពស់បំផុតតាំងតែពីឆ្នាំ២០១៥។

ទិន្នន័យសម្រាប់ខែមិថុនា ត្រូវបានពិនិត្យវាយតម្លៃសារឡើងវិញដែលបានបង្ហាញឲ្យឃើញថា ទំហំនៃឱនភាពពាណិជ្ជកម្មមានចំនួនត្រឹមតែ ៤៥,៧ពាន់លានដុល្លា ជំនួសឲ្យ ៤៦,៣ពាន់លានដុល្លា តាមសេចក្តីរាយការណ៍ពីមុន។

បន្ទាប់ពីធ្វើការកែតម្រូវអតិផរណា គម្លាតពាណិជ្ជកម្មសម្រាប់រយៈពេល៥ខែបានកើនឡើងដល់កម្រិតខ្ពស់ ពី៧៩,៣ពាន់លានដុល្លាក្នុងខែមិថុនា ដល់ ៨២,៥ពាន់លានដុល្លាក្នុងខែកក្កដា។ ឱនភាពពាណិជ្ជកម្មពិតរបស់ខែកក្កដា គឺលើសពីមធ្យមភាគត្រីមាសទីពីរដែលស្មើនឹង ៧៧,៥ពាន់លានដុល្លា ហើយប្រសិនបើលទ្ធផលនេះបន្តទៅមុខ ចំពោះខែដែលនៅសល់ក្នុងត្រីមាសនេះ ពាណិជ្ជកម្មអន្តរជាតិអាចនឹងដកពីផ.ស.ស.នៃត្រីមាសទីបី។

# ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អត្រាអតិផរណា និងផលិតកម្មឧស្សាហកម្មរបស់សហរដ្ឋអាមេរិក និងអត្រាគ្មានការងាររបស់ប្រទេសសិង្ហបុរី និងប្រទេសកូរ៉េខាងត្បូង។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី ១០ ខែកញ្ញា

- គណនីចរន្តរបស់ប្រទេសជប៉ុន សម្រាប់ខែកក្កដា
- ការប៉ាន់ស្មានចុងក្រោយ ផ.ស.ស របស់ប្រទេសជប៉ុន សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៨
- អត្រាអតិផរណារបស់ប្រទេសចិន សម្រាប់ខែសីហា
- ការវិនិយោគដោយផ្ទាល់ពីបរទេសរបស់ប្រទេសហ្វីលីពីន សម្រាប់ខែមិថុនា
- ទិន្នន័យលក់រាយរបស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែកក្កដា
- ការរំពឹងទុកអត្រាអតិផរណារបស់អ្នកប្រើប្រាស់ សម្រាប់សហរដ្ឋអាមេរិក នៅខែសីហា

<u>ថ្ងៃអង្គារ ទី១១ ខែកញ្ញា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសហ្វីលីពីន សម្រាប់ខែកក្កដា
- ការដេញថ្លៃសញ្ញាណប័ណ្ណរយៈពេល៣០ឆ្នាំ របស់រដ្ឋាភិបាលប្រទេសជប៉ុន
- ទិន្នន័យនៃការបើកឱកាសការងាររបស់សហរដ្ឋអាមេរិក សម្រាប់ខែកក្កដា

<u>ថ្ងៃពុធ ទី១២ ខែកញ្ញា</u>

- ទិន្នន័យនៃការផ្លាស់ប្តូរស្តុកប្រេងឆៅរបស់វិទ្យាស្ថានប្រេងឥន្ទនៈអាមេរិកាំង(API) របស់សហរដ្ឋអាមេរិចក្នុងថ្ងៃទី៧ ខែកញ្ញា
- អត្រានិកម្មភាពរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែសីហា
- សន្ទស្សន៍ឧស្សាហកម្មសេវាកម្មរបស់ប្រទេសជប៉ុន សម្រាប់ខែកក្កដា
- ទិន្នន័យលក់រាយរបស់ប្រទេសសឹង្ហបុរីសម្រាប់ខែកក្កដា
- សន្ទស្សន៍តម្លៃគោលសម្រាប់អ្នកផលិត និងសន្ទស្សន៍តម្លៃសម្រាប់អ្នកផលិតរបស់សហរដ្ឋអាមេរិក សម្រាប់ខែសីហា

<u>ថ្ងៃព្រហស្បត្តិ៍ ទី ១៣ ខែកញ្ញា</u>

- ទិន្នន័យការវិនិយោគភាគហ៊ុនដោយជនបរទេសរបស់ប្រទេសជប៉ុន ក្នុងថ្ងៃទី៨ ខែកញ្ញា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិតរបស់ប្រទេសជប៉ុន សម្រាប់ខែសីហា
- អត្រានិកម្មភាពរបស់ប្រទេសសឹង្ហបុរី សម្រាប់ត្រីមាសទី២
- ទិន្នន័យលក់រាយរបស់ប្រទេសម៉ាឡេស៊ី សម្រាប់ខែកក្កដា
- ទិន្នន័យការផ្គត់ផ្គង់រូបិយវត្ថុ(M2)របស់ចិន សម្រាប់ខែសីហា
- អត្រាអតិផរណារបស់សហរដ្ឋអាមេរិក សម្រាប់ខែសីហា

<u>ថ្ងៃសុក្រ ទី ១៤ ខែកញ្ញា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែសីហា
- ផលិតកម្មឧស្សាហកម្មរបស់ប្រទេសចិន សម្រាប់ខែសីហា
- អត្រានិកម្មភាពនៅប្រទេសម៉ាឡេស៊ី សម្រាប់ខែកក្កដា
- ផលិតកម្មឧស្សាហកម្មរបស់សហរដ្ឋអាមេរិក សម្រាប់ខែសីហា